ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១១-៨-២០០៩ -ព្រះរាជក្រម នស/រកម/០៨០៩/០១៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីអនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ ៥៩៧៤


### ២~ព្រះរាជក្រឹត្យ


១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៣ ស្តីពីការតម្លើងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម ចំនួន ០៧ រូប,ក្រសួងអប់រំយុវជន និង កីឡា ចំនួន ០១ រូប ,ក្រសួងព័ត៌មាន ចំនួន ០៨ រូប ៥៩៥០

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៤ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក អេខ ថន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៥៩៥៣

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៥ ស្តីពីការតែងតាំងឯកឧត្តម ព្រុំ សុគមង្គល ជាអគ្គលេខាធិការរងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីនមានឋានៈស្មើអនុរដ្ឋលេខាធិការ ៥៩៥៤

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៦ ស្តីពីការតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូនចំនួន ០៧ រូប និង ក្រសួងអភិវឌ្ឍន៍ជនបទចំនួន ០៤ រូប ៥៩៥៥

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៧ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហាន កងទ័ពជើងគោក និង កងទ័ពជើងអាកាស ចំនួន ០២ រូប ៥៩៥៧

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៨ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិអេស្កាប់ ចំនួន ១៩ រូប ៥៩៥៨

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១៩ ស្តីពីការតែងតាំងឯកឧត្តម គី ធីតា ជា ឧកញ៉ា ៦០០០


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១២-៨-២០០៩ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទៃកពាណិជ្ជកម្ម ៦០០១

១២-៨-២០០៩ -អនុក្រឹត្យលេខ ១២៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦០១៧
១២-៨-២០០៩ -អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការគ្រប់គ្រង និង ប្រើប្រាស់អគារសហកម្មសិទ្ធិ ៦០១៩
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៣៨
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៤៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦០៤០
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៤៨
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៥០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៤៩
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៥១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៥០
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៥២ អនក្រ.តត ស្តីពីការតម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ ៦០៥១
២៧-៧-២០០៩ -អនុក្រឹត្យលេខ១២៥៣ អនក្រ.តត ស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ៦០៥២
២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៥៤ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៦០៥៣
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៥៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៦០៥៤
*-អនុក្រឹត្យលេខ ១២៥៦ អនក្រ.តត មិនទាន់បានទទួល*
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៥៧ អនក្រ.តត ស្តីពីការលុបឈ្មោះនាយទាហាន ៦០៥៥
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៥៦
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៥៨
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៦០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦០៥៩
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៦១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦០៦០
២៨-៧-២០០៩ -អនុក្រឹត្យលេខ ១២៦២ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦០៦១
២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦០៦៣
២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦០៦៤
២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៦៥

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៥-៨-២០០៩ -ប្រកាសលេខ ៦៨០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជ្រេហ្គនថេក មេនូហ្វេកឈ័រ បង្កើតរោងចក្រ "ផលិតសម្លៀកបំពាក់" ៦០៦៦

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

១៧-៨-២០០៩ -ប្រកាសលេខ ១០៥ ប្រក ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ ៦០៧១

១៧-៨-២០០៩ -ប្រកាសលេខ ១០៦ ប្រក ស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយ ១ ផ្កាយ ២ ផ្កាយ ៣ ផ្កាយ ៤ និង ផ្កាយ ៥ ៦០៧៤
១៧-៨-២០០៩ -សារាចរណែនាំលេខ ០០៤ សរណន ស្តីពីការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ ៦០៧៧

## ៣-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល

១៣-៨-២០០៩ -សារាចរណែនាំលេខ ០៤២១ អបស/ឱអបស ស្តីពីការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនភោជនីយដ្ឋាន-អាហារដ្ឋាន ៦០៨០

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃ
# អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃ
# ការរើសអើងប្រឆាំងនឹងនារីភេទ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលធ្វើនៅទីក្រុងញូយ៉ក នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារតាមជម្រើសនៃអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

នស/រកម.០៨០៩.០៣៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

ហត្ថលេខា

អ៊ឹង កន្ថាផាវី

លេខ : ៧៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ពិធីសារនាមជម្រើស
# នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ
## (Optional Protocol of CEDAW)

*អនុម័តដោយសេចក្តីសម្រេចចិត្តលេខ A/54/4 នៃមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៩ និងបើកចំហសម្រាប់ការចុះហត្ថលេខានៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលជាទិវាសិទ្ធិមនុស្ស ចូលជាធរមាននៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០០ (តាមមាត្រា ១៦)*

រដ្ឋភាគីទាំងឡាយនៃពិធីសារនេះ,

*ដោយកត់សំគាល់ថា* ធម្មនុញ្ញអង្គការសហប្រជាជាតិ អះអាងឡើងវិញនូវជំនឿលើសិទ្ធិមនុស្ស ជាមូលដ្ឋាននៃសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់មនុស្ស និងសិទ្ធិស្មើគ្នារបស់បុរស និងស្ត្រី

*ដោយកត់សំគាល់ផងដែរថា* សេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្ស នៅក្នុងសេចក្តីសម្រេចចិត្ត-លេខ 217A ( III ) ប្រកាសថា មនុស្សជាតិគ្រប់រូបកើតមកជាមួយនឹងសេរីភាព និងភាពស្មើគ្នាក្នុង សេចក្តីថ្លៃថ្នូរ និងសិទ្ធិនានា និងថាបុគ្គលគ្រប់រូបមានសិទ្ធិទទួលនូវសិទ្ធិនានា និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្សខាងលើដោយគ្មានការរើសអើង រាប់បញ្ចូលទាំងការរើសអើងភេទផងនោះ

*ដោយចងចាំថា* កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្ស នៅក្នុងសេចក្តីសម្រេចលេខ ២២០០ A ( XXI ) ក្នុងឧបសម្ព័ន្ធ និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត ហាមឃាត់ការរើសអើងភេទ

*ដោយចងចាំផងដែរថា* អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ “ អនុសញ្ញា ” ដែលក្នុងនោះរដ្ឋភាគីធានាថ្កោលទោសរាល់ទម្រង់ទាំងអស់នៃការរើសអើងប្រឆាំងនារីភេទ និងយល់ព្រមបន្តអនុវត្តគោលនយោបាយនៃការលុបបំបាត់នូវការរើសអើងប្រឆាំងនារីភេទ ដោយមធ្យោបាយសមស្របគ្រប់បែបយ៉ាង និងដោយគ្មានការបង្អែរបង្អង់

*ដោយអះអាងឡើងវិញ* នូវការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីធានាថា ស្ត្រីទទួលបាននូវសិទ្ធិ និងសេរីភាព ជាមូលដ្ឋានទាំងអស់ដោយពេញលេញ និងដោយស្មើភាព ហើយចាត់ការដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភសិទ្ធិ និងសេរីភាពទាំងឡាយ

*បានព្រមព្រៀងគ្នាដូចតទៅ* :

## មាត្រា ១

*រដ្ឋភាគីមួយនៃពិធីសារនេះ ( រដ្ឋភាគី )* ទទួលស្គាល់នូវសមត្ថកិច្ចរបស់គណៈកម្មាធិការ ស្តីពីការលុបបំបាត់ចោលនូវការរើសអើងប្រឆាំងនារីភេទ ( គណៈកម្មាធិការ ) ដើម្បីទទួល និងពិចារណាលើលិខិតបណ្តឹងនានាដែលត្រូវបានដាក់ជូនគណៈកម្មាធិការ ស្របតាមមាត្រា ២ ។

## មាត្រា ២

លិខិតបណ្តឹងទាំងនេះ អាចត្រូវបានដាក់ជូនដោយ ឬ ក្នុងនាមបុគ្គលម្នាក់ៗ ឬក្រុមនៃបុគ្គលដែលស្ថិតនៅក្រោម *យុត្តាធិការ* របស់រដ្ឋភាគី ដោយបានទាមទារថា ពួកគេរងគ្រោះដោយការរំលោភសិទ្ធិណាមួយ ដែលមានចែងនៅក្នុងអនុសញ្ញាដោយរដ្ឋភាគីនោះ ។ នៅកន្លែងដែលលិខិតបណ្តឹងត្រូវបានដាក់ជូនប្តឹងក្នុងនាមបុគ្គល ឬក្រុមនៃបុគ្គល ត្រូវមានការយល់ព្រមពីពួកគេទាំងនោះ ឬយ៉ាងហោចណាស់លុះត្រាតែអ្នកសរសេរលិខិតបណ្តឹង នោះអាចបញ្ជាក់ថាខ្លួនដើរតួប្តឹងជំនួសពួកគេ បើពុំមានការយល់ព្រមទេ ។

## មាត្រា ៣

លិខិតបណ្តឹងទាំងនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមិនត្រូវធ្វើជាលក្ខណៈអនាមិកឡើយ ។ គណៈកម្មាធិការនឹងមិនទទួលលិខិតបណ្តឹងឡើយ ប្រសិនបើលិខិតបណ្តឹងនោះពាក់ព័ន្ធនឹងរដ្ឋភាគីមួយនៃអនុសញ្ញា តែមិនមែនជាភាគីនៃពិធីសារនេះ ។

## មាត្រា ៤

១. គណៈកម្មាធិការនឹងមិនពិចារណាលើលិខិតបណ្តឹងឡើយ ប្រសិនបើដឹងប្រាកដថា ដំណោះស្រាយទាំងអស់ដែលមាននៅក្នុងប្រទេស មិនទាន់ត្រូវបានប្រើប្រាស់ឱ្យអស់លទ្ធភាព ឬការអនុវត្តដំណោះស្រាយទាំងនោះត្រូវបានអូសបន្លាយដោយមិនសមហេតុផល ឬមិនទំនងជាអាចនាំមកនូវភាពធូរស្រាលប្រកបដោយប្រសិទ្ធភាពបានទេ ។

២. គណៈកម្មាធិការនឹងអាចប្រកាសថា លិខិតបណ្តឹងមិនអាចទទួលយកបាន ប្រសិនបើ :

(ក) បញ្ហាដដែលនោះ ត្រូវបានពិនិត្យដោយគណៈកម្មាធិការរួចហើយ ឬក៏បាននិងកំពុងពិនិត្យ ឬកំពុងពិនិត្យ ក្រោមនីតិវិធីនៃការស៊ើបអង្កេតជាអន្តរជាតិ ឬដំណោះស្រាយអន្តរជាតិមួយផ្សេងទៀត

(ខ) លិខិតបណ្តឹងនោះ មិនស្របនូវជាមួយបញ្ញត្តិនានានៃអនុសញ្ញា

(គ) លិខិតបណ្តឹងនោះ មិនមានមូលដ្ឋានត្រឹមត្រូវជាក់ស្តែង ឬមិនមានភស្តុតាងគ្រប់គ្រាន់

(ឃ) គឺជាការរំលោភបំពានលើសិទ្ធិក្នុងការដាក់លិខិតបណ្តឹង

(ង) ហេតុការណ៍នានាដែលជាប្រធានបទនៃលិខិតបណ្តឹងនោះ បានកើតឡើងមុនពិធីសារនេះចូលជាចូលជាធរមានសម្រាប់សាមីរដ្ឋភាគី ទោះបីជាហេតុការណ៍ទាំងនោះបានបន្តក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ ។

## មាត្រា ៥

១. នៅពេលណាមួយ ក្រោយពីទទួលបាននូវលិខិតបណ្តឹង និងមុនពេលឈានដល់ការសម្រេចលើអង្គហេតុ គណៈកម្មាធិការអាចផ្ញើបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ សម្រាប់ពិនិត្យពិចារណាជាបន្ទាន់លើសំណើដែលរដ្ឋភាគីនោះ ត្រូវចាត់វិធានការបណ្តោះអាសន្ន ដែលចាំបាច់ដើម្បីចៀសវាងការខូចខាតដែលមិនអាចប៉ះប៉ូវបានចំពោះជនរងគ្រោះ ឬជនរងគ្រោះទាំងឡាយដែលគេចោទថា បានត្រូវរំលោភ ។

២. នៅពេលដែលគណៈកម្មាធិការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះ នេះមិនមែនមានន័យថាជាការសម្រេចលើភាពអាចទទួលយកបាន ឬលើអង្គហេតុនៃលិខិតបណ្តឹងនោះទេ ។

## មាត្រា ៦

១. ទោះបីគណៈកម្មាធិការពិនិត្យឃើញថា លិខិតបណ្តឹងមិនអាចយកជាការបានដោយគ្មានការយោងទៅលើសាមីរដ្ឋភាគីនោះ ប៉ុន្តែបើបុគ្គលម្នាក់ ឬបុគ្គលជាច្រើនយល់ព្រមបង្ហាញអត្តសញ្ញាណរបស់ពួកគេដល់រដ្ឋភាគីនោះ គណៈកម្មាធិការនឹងបញ្ជូនទៅសាមីរដ្ឋភាគីដោយសម្ងាត់នូវលិខិតបណ្តឹងដែលបានដាក់ជូនគណៈកម្មាធិការក្រោមពិធីសារនេះ ។

២. ក្នុងអំឡុងពេលប្រាំមួយខែ រដ្ឋភាគីដែលបានទទួលលិខិតបណ្តឹងពីគណៈកម្មាធិការ ត្រូវដាក់ជូនគណៈកម្មាធិការនូវការពន្យល់ ឬសេចក្តីថ្លែងការណ៍នានាជាលាយលក្ខណ៍អក្សរបំភ្លឺអំពីបញ្ហាខាងលើ និងដំណោះស្រាយ *(ប្រសិនបើមាន)* ដោយរដ្ឋភាគីនោះ ។

## មាត្រា ៧

១. គណៈកម្មាធិការនឹងពិចារណាលើលិខិតបណ្តឹងដែលខ្លួនបានទទួល ដូចមានចែងនៅក្នុងពិធីសារនេះ ទន្ទឹមនឹងព័ត៌មានទាំងអស់ដែលបានផ្តល់ជូនដោយ ឬក្នុងនាមបុគ្គលម្នាក់ ឬក្រុមនៃបុគ្គលក្តី និងដោយសាមីរដ្ឋភាគីក្តី ឱ្យតែព័ត៌មានទាំងនេះបានបញ្ជូនដល់ភាគីពាក់ព័ន្ធទាំងឡាយ ។

២. គណៈកម្មាធិការ ត្រូវរៀបចំការប្រជុំសម្ងាត់នៅពេលដែលខ្លួនកំពុងពិនិត្យលើលិខិតបណ្តឹងនានាក្រោមពិធីសារនេះ ។

៣. ក្រោយពីការពិនិត្យលិខិតបណ្តឹងនេះ គណៈកម្មាធិការត្រូវបញ្ជូនយោបល់នានារបស់ខ្លួនស្តីពីលិខិតបណ្តឹងទាំងនេះ ព្រមទាំងអនុសាសន៍នានា *(ប្រសិនបើមាន)* ទៅភាគីទាំងឡាយដែលពាក់ព័ន្ធ។

៤. រដ្ឋភាគី ត្រូវផ្តល់ការពិចារណា ក្នុងរយៈពេលមួយជាក់លាក់លើយោបល់នានារបស់គណៈកម្មាធិការ ព្រមទាំងអនុសាសន៍ផង និងត្រូវដាក់ជូនគណៈកម្មាធិការនូវចម្លើយជាលាយលក្ខណ៍អក្សរ រាប់បញ្ចូលទាំងព័ត៌មាន ស្តីពីចំណាត់ការណាមួយដែលបានចាត់ឡើងពាក់ព័ន្ធនឹងយោបល់ និងអនុសាសន៍របស់គណៈកម្មាធិការក្នុងរយៈពេលប្រាំមួយខែ ។

៥. គណៈកម្មាធិការ អាចស្នើសុំរដ្ឋភាគីឱ្យដាក់ជូននូវព័ត៌មានបន្ថែមអំពីវិធានការទាំងឡាយដែលរដ្ឋភាគីបានចាត់ការហើយ ឆ្លើយតបទៅនឹងយោបល់ ឬអនុសាសន៍នានារបស់ខ្លួន (ប្រសិនបើមាន) រួមទាំងអ្វីៗដែលគណៈកម្មាធិការយល់ថា ជាការសមស្របទៅក្នុងរបាយការណ៍លើកក្រោយរបស់រដ្ឋភាគីស្របតាមមាត្រា១៨ នៃអនុសញ្ញា ។

## មាត្រា ៨

១. ប្រសិនបើគណៈកម្មាធិការទទួល ព័ត៌មានដែលគួរឱ្យជឿទុកចិត្តបានបង្ហាញពីការរំលោភ-សិទ្ធិធ្ងន់ធ្ងរ ឬមានលក្ខណៈជាប្រព័ន្ធដែលមានចែងនៅក្នុងអនុសញ្ញា គណៈកម្មាធិការនឹងស្នើសុំរដ្ឋភាគីនោះ ឱ្យជួយសហការក្នុងការត្រួតពិនិត្យព័ត៌មាន ហើយចុងបញ្ចប់ដាក់ជូននូវកត់សម្គាល់ទាំងឡាយទាក់ទិននឹងព័ត៌មាននោះ ។

២. ដោយពិចារណាលើមតិដែលបានមកពីការកត់សម្គាល់ ដែលអាចត្រូវបានដាក់ជូនដោយសាមីរដ្ឋភាគីក៏ដូចជាព័ត៌មានដែលគួរឱ្យជឿទុកចិត្តបានណាមួយផ្សេងទៀត ដែលខ្លួនមាននោះ *គណៈកម្មាធិការ* អាចជ្រើសតាំងសមាជិករបស់ខ្លួនម្នាក់ ឬច្រើនអ្នកដើម្បីដឹកនាំធ្វើការស៊ើបអង្កេត និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ ។ ការស៊ើបអង្កេតអាចរាប់បញ្ចូលទស្សនកិច្ចទៅកាន់ដែនដីនៃរដ្ឋភាគីដែលត្រូវធានា និងយល់ព្រមដោយរដ្ឋភាគីនោះផង ។

៣. ក្រោយពីពិនិត្យលើលទ្ធផលនៃការស៊ើបអង្កេតបែបនោះ *គណៈកម្មាធិការ* នឹងផ្ញើលទ្ធផលទាំងនេះឱ្យទៅសាមីរដ្ឋភាគីរួមជាមួយនឹងយោបល់ និងអនុសាសន៍ផ្សេងៗផង ។

៤. សាមីរដ្ឋភាគី ក្នុងរយៈពេលប្រាំមួយខែនៃការទទួលលទ្ធផល យោបល់ និងអនុសាសន៍នានាដែលគណៈកម្មាធិការបានផ្ញើជូន ត្រូវដាក់ជូនគណៈកម្មាធិការនូវកំណត់សម្គាល់របស់ខ្លួន ។

៥. ការស៊ើបអង្កេតបែបនោះនឹងត្រូវធ្វើឡើងយ៉ាងសម្ងាត់ ហើយកិច្ចសហប្រតិបត្តិការរបស់រដ្ឋ-ភាគីនឹងត្រូវបានផ្តល់នៅគ្រប់ដំណាក់កាលនៃដំណើរការប្តឹងទាំងនោះ ។

## មាត្រា ៩

១. *គណៈកម្មាធិការ* អាចស្នើសាមីរដ្ឋភាគីឱ្យបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន តាមមាត្រា ១៨ នៃអនុសញ្ញា នូវវិធានការណាមួយដែលខ្លួនបានចាត់ការរួចដោយលំអិត ឆ្លើយតបទៅនឹងការស៊ើប-អង្កេត ដែលធ្វើឡើងតាមមាត្រា ៨ នៃពិធីសារនេះ ។

២. *គណៈកម្មាធិការ* អាចក្នុងករណីចាំបាច់ ស្នើឱ្យសាមីរដ្ឋភាគីផ្តល់ព័ត៌មានដល់ខ្លួន អំពីវិធានការទាំងឡាយដែលត្រូវបានចាត់ការរួច ឆ្លើយតបទៅនឹងការស៊ើបអង្កេតនោះក្រោយពីបញ្ចប់នៃរយៈពេល-ប្រាំមួយខែ ដែលបានចែងនៅក្នុងមាត្រា ៨.៤ ។

## មាត្រា ១០

១. រដ្ឋភាគីនីមួយៗអាច នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័នពិធីសារនេះ ឬចូលពិធីសារនេះ ប្រកាសថាខ្លួនមិនទទួលស្គាល់នូវសមត្ថកិច្ចរបស់គណៈកម្មាធិការ ដែលបានចែងនៅក្នុងមាត្រា ៨ និង ៩ ខាងលើ ។

២. រដ្ឋភាគីណាមួយដែលបានធ្វើការប្រកាស ស្របតាមវាក្យខណ្ឌ ១ នៃមាត្រានេះ អាចដកសេចក្តីប្រកាសនេះចេញនៅពេលណាមួយក៏បាន ដោយការជូនដំណឹងដល់អគ្គលេខាធិការ ។

## មាត្រា ១១

រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាថា បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោម *យុត្តាធិការ* របស់រដ្ឋភាគី មិនត្រូវទទួលរងនូវអំពើអាក្រក់ ឬការបំភិតបំភ័យ ដែលជាផលវិបាកបណ្តាលមកពីការប្តឹងទៅគណៈកម្មាធិការឡើយ ដោយអនុលោមតាមពិធីសារនេះ ។

## មាត្រា ១២

គណៈកម្មាធិការនឹងបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន នូវសេចក្តីសង្ខេបមួយនៃសកម្មភាពរបស់ខ្លួនស្ថិតក្រោមពិធីសារនេះ ស្របតាមមាត្រា ២១ នៃអនុសញ្ញា។

## មាត្រា ១៣

រដ្ឋភាគីនីមួយៗ ទទួលរ៉ាប់រងផ្សព្វផ្សាយអនុសញ្ញា និងពិធីសារនេះឱ្យសាធារណៈជនបានដឹងយ៉ាងទូលំទូលាយ និងសម្រួលយ៉ាងណាឱ្យប្រព័ន្ធព័ត៌មានទទួលបានយោបល់ និងអនុសាសន៍នានារបស់គណៈកម្មាធិការ ជាពិសេសអំពីបញ្ហាទាំងឡាយដែលទាក់ទិននឹងរដ្ឋភាគីនោះ ។

## មាត្រា ១៤

គណៈកម្មាធិការត្រូវរៀបចំបង្កើតវិធាននីតិវិធីរបស់ខ្លួនដើម្បីប្រតិបត្តិតាម នៅពេលអនុវត្តមុខងារទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យដោយពិធីសារ ។

## មាត្រា ១៥

១. ពិធីសារនេះនឹងបើកចំហសំរាប់ការចុះហត្ថលេខាដោយរដ្ឋណាមួយ ដែលបានចុះហត្ថលេខា បានផ្តល់សច្ចាប័ន ឬចូលអនុសញ្ញា ។

២. ពិធីសារនេះ ត្រូវតែមានការផ្តល់សច្ចាប័នដោយរដ្ឋភាគីដែលបានផ្តល់សច្ចាប័ន ឬបានចូលអនុសញ្ញា ។ លិខិតុបករណ៍នានានៃការផ្តល់សច្ចាប័ននឹងត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

៣. ពិធីសារបច្ចុប្បន្ន នឹងបើកចំហសម្រាប់ការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុន ដោយរដ្ឋណាមួយដែលបានផ្តល់សច្ចាប័ន ឬបានចូលអនុសញ្ញា ។

៤. ការចូលអនុសញ្ញានឹងត្រូវចូលជាធរមាន ដោយការតម្កល់ទុកលិខិតុបករណ៍នៃការចូលជាមួយអគ្គលេខាធិការនៃអង្គការ សហប្រជាជាតិ ។

## មាត្រា ១៦

១. ពិធីសារបច្ចុប្បន្ននឹងចូលជាធរមានក្នុងរយៈពេលបីខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនូវលិខិតុបករណ៍ទី ១០ នៃការផ្តល់សច្ចាប័ន ឬការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុន ។

២. សម្រាប់រដ្ឋនីមួយៗ ដែលបានផ្តល់សច្ចាប័ន ឬបានផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនលើពិធីសារនេះ បន្ទាប់ពីពិធីសារបច្ចុប្បន្នបានចូលជាធរមានហើយ ពិធីសារបច្ចុប្បន្ននឹងចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយពីកាលបរិច្ឆេទនៃការដំកល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនរបស់ខ្លួនផ្ទាល់ ។

## មាត្រា ១៧

ពិធីសារនេះមិនអនុញ្ញាតឱ្យមានការដាក់ល័ក្ខខ័ណ្ឌ ឬរក្សាទុកឡើយ ។

## មាត្រា ១៨

១. រដ្ឋភាគីណាមួយក៏ដោយ អាចស្នើសុំធ្វើវិសោធនកម្មចំពោះពិធីសារនេះហើយដាក់សំណើនេះជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិបាន ។ នៅពេលនោះ អគ្គលេខាធិការនឹងផ្ញើសំណុំ-

ឯកសារស្នើសុំធ្វើវិសោធនកម្ម នេះទៅរដ្ឋភាគីទាំងឡាយជាមួយនឹងសំណូមពរមួយសុំឱ្យពួកគេកត់-សម្គាល់ខ្លួនឯង ថាតើពួកគេគាំទ្រឱ្យមានសន្និសីទមួយរបស់រដ្ឋភាគីទាំងឡាយក្នុងគោលបំណងពិចារណា និងបោះឆ្នោតលើសំណើនោះដែរឬអត់ ។ ក្នុងករណី ១/៣ យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានសន្និសីទបែប-នោះ *អគ្គលេខាធិការ* នឹងកោះអញ្ជើញរដ្ឋភាគីសម្រាប់សន្និសីទនោះ ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ វិសោធនកម្មណាមួយ ដែលត្រូវបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងសន្និសីទនោះនឹងត្រូវបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីសម្រេច ។

២. វិសោធនកម្មនានានឹងចូលជាធរមាននៅពេលដែលវិសោធនកម្មទាំងនោះ ត្រូវបានសម្រេចដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ និងទទួលយកដោយមតិភាគច្រើន ២/៣ នៃរដ្ឋភាគីចំពោះពិធីសារនេះ អនុលោមទៅតាមដំណើរការនានានៃរដ្ឋធម្មនុញ្ញរៀងៗខ្លួនរបស់រដ្ឋភាគីទាំងឡាយនោះ ។

៣. នៅពេលដែលវិសោធនកម្មនានាចូលជាធរមាន វិសោធនកម្មទាំងនោះនឹងចងភ្ជាប់ជាមួយកាតព្វកិច្ចរបស់រដ្ឋភាគីទាំងឡាយដែលបានទទួលយកវិសោធនកម្មទាំងនោះ រដ្ឋភាគីផ្សេងទៀតនៅតែជាប់កាតព្វកិច្ចចំពោះបញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មពីមុនណាមួយដែលរដ្ឋភាគីទាំងនោះ បាន-ទទួលយករួចហើយ ។

## មាត្រា ១៩

១. រដ្ឋភាគីនីមួយៗ អាចប្រកាសមិនយល់ព្រមចំពោះពិធីសារនេះនៅពេលណាមួយក៏បាន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ ការប្រកាសមិនយល់ព្រមនឹងចូលជាធរមានក្នុងរយៈពេល *ប្រាំមួយខែ* បន្ទាប់ពីថ្ងៃដែលអគ្គលេខាធិការបានទទួលការជូន-ដំណឹងនោះពីរដ្ឋភាគី ។

២. ការប្រកាសមិនយល់ព្រម ត្រូវតែមិនមានការលំអៀងទៅរកការអនុវត្តដែលត្រូវបន្តនៃបញ្ញត្តិនានានៃពិធីសារនេះ ចំពោះលិខិតបណ្តឹងណាមួយដែលត្រូវបានដាក់ជូនមកគណៈកម្មាធិការ ក្រោមមាត្រា ២ ឬការស៊ើបអង្កេតណាមួយដែលត្រូវបានផ្តួចផ្តើមគំនិតក្រោមមាត្រា ៨ មុនថ្ងៃចូលជាធរមាននៃការប្រកាសមិនយល់ព្រមនោះ ។

## មាត្រា ២០

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់អំពី :

(ក) ការចុះហត្ថលេខានានា ការផ្តល់សច្ចាប័ននានា និងការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនទាំងឡាយ ក្រោមពិធីសារនេះ

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ និងនៃការធ្វើវិសោធនកម្មណាមួយនៅក្រោមមាត្រា ១៨

(គ) ការប្រកាសមិនយល់ព្រមណាមួយ ក្រោមមាត្រា ១៩ ។

## មាត្រា ២១

១. ពិធីសារនេះ ដែលឯកសារដើមជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្បាញ៉ុល មានតម្លៃស្មើគ្នានោះ ត្រូវបានតម្កល់ទុកនៅក្នុងបណ្ណសាររបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិនឹងផ្ញើច្បាប់នៃពិធីសារនេះ ដែលមានការបញ្ជាក់ថាត្រឹមត្រូវជូនរដ្ឋទាំងអស់ យោងទៅតាមមាត្រា ២៥ នៃអនុសញ្ញា ។

**Optional Protocol to the Convention on the Elimination of Discrimination against Women**
**Adopted by General Assembly resolution A/54/4 on 6 October 1999 and opened for signature on 10 December 1999, Human Rights Day entry into force 22 December 2000**

The States Parties to the present Protocol,

*Noting* that the Charter of the United Nations reaffirms faith in fundamental human rights, in the dignity and worth of the human person and in the equal rights of men and women,

*Also noting* that the Universal Declaration of Human Rights Resolution 217 A (III). proclaims that all human beings are born free and equal in dignity and rights and that everyone is entitled to all the rights and freedoms set forth therein, without distinction of any kind, including distinction based on sex,

*Recalling* that the International Covenants on Human Rights Resolution 2200 A (XXI), annex. and other international human rights instruments prohibit discrimination on the basis of sex,

*Also recalling* the Convention on the Elimination of All Forms of Discrimination against Women4 ("the Convention"), in which the States Parties thereto condemn discrimination against women in all its forms and agree to pursue by all appropriate means and without delay a policy of eliminating discrimination against women,

*Reaffirming* their determination to ensure the full and equal enjoyment by women of all human rights and fundamental freedoms and to take effective action to prevent violations of these rights and freedoms,

*Have agreed as follows:*

*Article 1*

A State Party to the present Protocol ("State Party") recognizes the competence of the Committee on the Elimination of Discrimination against Women ("the Committee") to receive and consider communications submitted in accordance with article 2.

*Article 2*

Communications may be submitted by or on behalf of individuals or groups of individuals, under the jurisdiction of a State Party, claiming to be victims of a violation of any of the rights set forth in the Convention by that State Party. Where a communication is submitted on behalf of individuals or groups of individuals, this shall be with their consent unless the author can justify acting on their behalf without such consent.

*Article 3*

Communications shall be in writing and shall not be anonymous. No communication shall be received by the Committee if it concerns a State Party to the Convention that is not a party to the present Protocol.

*Article 4*

1. The Committee shall not consider a communication unless it has ascertained that all available domestic remedies have been exhausted unless the application of such remedies is unreasonably prolonged or unlikely to bring effective relief.
2. The Committee shall declare a communication inadmissible where:
(a) The same matter has already been examined by the Committee or has been or is being examined under another procedure of international investigation or settlement;
(b) It is incompatible with the provisions of the Convention;
(c) It is manifestly ill-founded or not sufficiently substantiated;
(d) It is an abuse of the right to submit a communication;
(e) The facts that are the subject of the communication occurred prior to the entry into force of the present Protocol for the State Party concerned unless those facts continued after that date.

*Article 5*

1. At any time after the receipt of a communication and before a determination on the merits has been reached, the Committee may transmit to the State Party concerned for its urgent consideration a request that the State Party take such interim measures as may be necessary to avoid possible irreparable damage to the victim or victims of the alleged violation.

2. Where the Committee exercises its discretion under paragraph 1 of the present article, this does not imply a determination on admissibility or on the merits of the communication.

*Article 6*

1. Unless the Committee considers a communication inadmissible without reference to the State Party concerned, and provided that the individual or individuals consent to the disclosure of their identity to that State Party, the Committee shall bring any communication submitted to it under the present Protocol confidentially to the attention of the State Party concerned.

2. Within six months, the receiving State Party shall submit to the Committee written explanations or statements clarifying the matter and the remedy, if any, that may have been provided by that State Party.

*Article 7*

1. The Committee shall consider communications received under the present Protocol in the light of all information made available to it by or on behalf of individuals or groups of individuals and by the State Party concerned, provided that this information is transmitted to the parties concerned.

2. The Committee shall hold closed meetings when examining communications under the present Protocol.

3. After examining a communication, the Committee shall transmit its views on the communication, together with its recommendations, if any, to the parties concerned.

4. The State Party shall give due consideration to the views of the Committee, together with its recommendations, if any, and shall submit to the Committee, within six months, a written response, including information on any action taken in the light of the views and recommendations of the Committee.

5. The Committee may invite the State Party to submit further information about any measures the State Party has taken in response to its views or recommendations, if any, including as deemed appropriate by the Committee, in the State Party's subsequent reports under article 18 of the Convention.

*Article 8*

1. If the Committee receives reliable information indicating grave or systematic violations by a State Party of rights set forth in the Convention, the Committee shall invite that State Party to cooperate in the examination of the information and to this end to submit observations with regard to the information concerned.

2. Taking into account any observations that may have been submitted by the State Party concerned as well as any other reliable information available to it, the Committee may designate one or more of its members to conduct an inquiry and to report urgently to the Committee. Where warranted and with the consent of the State Party, the inquiry may include a visit to its territory.

3. After examining the findings of such an inquiry, the Committee shall transmit these findings to the State Party concerned together with any comments and recommendations.

4. The State Party concerned shall, within six months of receiving the findings, comments and recommendations transmitted by the Committee, submit its observations to the Committee.

5. Such an inquiry shall be conducted confidentially and the cooperation of the State Party shall be sought at all stages of the proceedings.

*Article 9*

1. The Committee may invite the State Party concerned to include in its report under article 18 of the Convention details of any measures taken in response to an inquiry conducted under article 8 of the present Protocol.

2. The Committee may, if necessary, after the end of the period of six months referred to in article 8.4, invite the State Party concerned to inform it of the measures taken in response to such an inquiry.

*Article 10*

1. Each State Party may, at the time of signature or ratification of the present Protocol or accession thereto, declare that it does not recognize the competence of the Committee provided for in articles 8 and 9.

2. Any State Party having made a declaration in accordance with paragraph 1 of the present article may, at any time, withdraw this declaration by notification to the Secretary-General.

*Article 11*

A State Party shall take all appropriate steps to ensure that individuals under its jurisdiction are not subjected to ill treatment or intimidation as a consequence of communicating with the Committee pursuant to the present Protocol.

*Article 12*

The Committee shall include in its annual report under article 21 of the Convention a summary of its activities under the present Protocol.

*Article 13*

Each State Party undertakes to make widely known and to give publicity to the Convention and the present Protocol and to facilitate access to information about the views and recommendations of the Committee, in particular, on matters involving that State Party.

*Article 14*

The Committee shall develop its own rules of procedure to be followed when exercising the functions conferred on it by the present Protocol.

*Article 15*

1. The present Protocol shall be open for signature by any State that has signed, ratified or acceded to the Convention.

2. The present Protocol shall be subject to ratification by any State that has ratified or acceded to the Convention. Instruments of ratification shall be deposited with the Secretary-General of the United Nations.

3. The present Protocol shall be open to accession by any State that has ratified or acceded to the Convention.

4. Accession shall be effected by the deposit of an instrument of accession with the Secretary-General of the United Nations.

*Article 16*

1. The present Protocol shall enter into force three months after the date of the deposit with the Secretary-General of the United Nations of the tenth instrument of ratification or accession.

2. For each State ratifying the present Protocol or acceding to it after its entry into force, the present Protocol shall enter into force three months after the date of the deposit of its own instrument of ratification or accession.

*Article 17*

No reservations to the present Protocol shall be permitted.

*Article 18*

1. Any State Party may propose an amendment to the present Protocol and file it with the Secretary-General of the United Nations. The Secretary-General shall thereupon communicate any proposed amendments to the States Parties with a request that they notify her or him whether they favour a conference of States Parties for the purpose of considering and voting on the proposal. In the event that at least one third of the States Parties favour such a conference, the Secretary-General shall convene the conference under the auspices of the United Nations. Any amendment adopted by a majority of the States Parties present and voting at the conference shall be submitted to the General Assembly of the United Nations for approval.

2. Amendments shall come into force when they have been approved by the General Assembly of the United Nations and accepted by a two-thirds majority of the States Parties to the present Protocol in accordance with their respective constitutional processes.

3. When amendments come into force, they shall be binding on those States Parties that have accepted them, other States Parties still being bound by the provisions of the present Protocol and any earlier amendments that they have accepted.

*Article 19*

1. Any State Party may denounce the present Protocol at any time by written notification addressed to the Secretary-General of the United Nations. Denunciation shall take effect six months after the date of receipt of the notification by the Secretary-General.

2. Denunciation shall be without prejudice to the continued application of the provisions of the present Protocol to any communication submitted under article 2 or any inquiry initiated under article 8 before the effective date of denunciation.

*Article 20*

The Secretary-General of the United Nations shall inform all States of:
(a) Signatures, ratifications and accessions under the present Protocol;
(b) The date of entry into force of the present Protocol and of any amendment under article 18.
(c) Any denunciation under article 19.

*Article 21*

1. The present Protocol, of which the Arabic, Chinese, English, French, Russian and Spanish texts are equally authentic, shall be deposited in the archives of the United Nations.

2. The Secretary-General of the United Nations shall transmit certified copies of the present Protocol to all States referred to in article 25 of the Convention.

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា ភូតតក្ខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ចំនួន ០៧ រូប ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ០១ រូប ក្រសួងព័ត៌មានចំនួន ០៨ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| **ក្រសួងពាណិជ្ជកម្ម** | | | |
| ១ | ឯកឧត្ដម **សួស វណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៤ |
| ២ | ឯកឧត្ដម **សម សម្បត្តិ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៥ |
| ៣ | ឯកឧត្ដម **លី ផាណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៥ |
| ៤ | ឯកឧត្ដម **ពេជ ឫទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៥ |
| ៥ | ឯកឧត្ដម **សុខ សុភ័ក្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៦ |
| ៦ | ឯកឧត្ដម **ទេស អែតដា** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៦ |
| ៧ | ឯកឧត្ដម **មាន សុភា** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | | | |
| ៨ | ឯកឧត្ដម **អ៊ុន ថេវ** | ពីវរមន្ត្រី ថ្នាក់លេខ ១ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៣ |
| **ក្រសួងព័ត៌មាន** | | | |
| ៩ | ឯកឧត្ដម **ហ៊ឹម សួង** | ពីវរមន្ត្រី ថ្នាក់លេខ ១ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៣ |
| ១០ | លោកជំទាវ **លឹម មុំ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៤ |
| ១១ | ឯកឧត្ដម **សម សារិន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៤ |
| ១២ | ឯកឧត្ដម **សេង សារុន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៤ |
| ១៣ | ឯកឧត្ដម **ឃួន វិចិត្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៤ |
| ១៤ | ឯកឧត្ដម **លាង ប៊ុនរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៥ |
| ១៥ | លោកជំទាវ **ច័ន្ទ ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៦ |
| ១៦ | ឯកឧត្ដម **ហាស់ សំអាត** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្ដមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២ :** មន្ត្រីដែលត្រូវបានតម្លើងឋានន្តរសក្តិដូចមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រក. ០៩០៩. ៧២៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខ: ៧៦៨ ច.ល

**បានចម្លងចេញ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក អេង ថន

នូវ

គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៧.៧៤៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើត អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្ម មាត្រា ៤. មាត្រា ១០ និងមាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **ឡៅ សុភមង្គល** ជាអគ្គលេខាធិការរងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៩០៩.៩៧៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខ៖ ៧៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា, រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១** : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន គិតចាប់ពីថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៨ ដូចមានរាយនាមខាងក្រោម :

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ |
|---|---|---|---|
| ១ | ស្ងួន វិចិត្រ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២ | លន់ វិរៈវិចិត្រា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៣ | សិង ពន្លឺ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៤ | ទុំ សុវណ្ណ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៥ | ចឹម នូធា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៦ | សង់ ស៊ីណារ៉េត | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៧ | តី វឌ្ឍា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |

**មាត្រា ២** : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងអភិវឌ្ឍន៍ជនបទ គិតចាប់ពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ដូចមានរាយនាមខាងក្រោម :

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ |
|---|---|---|---|
| ១ | សាន ពិសិដ្ឋ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២ | ពេន វិញ្ញូ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៣ | សំ វឌ្ឍា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៤ | មឿន ស្រស់ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ៧. ០៩០៩. ៤ៃ៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខ: ៧២៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហាន កងទ័ពជើងគោក និង កងទ័ពជើងអាកាស ចំនួន ០២ រូប
១-ឧត្តមសេនីយ៍ត្រី **ស៊ិន ចំន្ទ** អត្តលេខ ០០១៩០៤
២-ឧត្តមសេនីយ៍ត្រី **ហ៊ំន សុផល** អត្តលេខ ០០០៩៧២

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៨០៩.៧៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខ: ៧៥៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០៩ / ០២៦ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអេស្កាប់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិអេស្កាប់ ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ចាន់ គីស៊ីម** | ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២. ឯកឧត្តម | **ទី តាឃី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣. ឯកឧត្តម | **ឯម សុភ័ណ្ឌ** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤. ឯកឧត្តម | **ស៊ិន ខំឈឿ** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៥. ឯកឧត្តម | **ឆា ចំនួលីជា** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦. ឯកឧត្តម | **ឡេង ធនយុទ្ធា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧. ឯកឧត្តម | **អ៊ិន ទិត្យធុរៈ** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨. ឯកឧត្តម | **សាន វណ្ណាធី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩. លោកជំទាវ | **ប្រាក់ ចំនួនណាយ** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១០. ឯកឧត្តម | **ហេង សុខគង់** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ១១. ឯកឧត្តម | **សេង លីម៉េង** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. ឯកឧត្តម | **ស្តើង សុខុម** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣. ឯកឧត្តម | **ហាក់ ស៊ីងលី** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤. ឯកឧត្តម | **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៥. ឯកឧត្តម | **មុំ ប៊ុនថន** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៦. ឯកឧត្តម | **ចាប ឫទ្ធី** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧. ឯកឧត្តម | **ស៊ា ហួង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៨. ឯកឧត្តម | **វ៉ុត ឌុន្នី** | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩. លោកជំទាវ | **យូ អយ** | ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក | សមាជិកអចិន្ត្រៃយ៍ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៧៧.០៩០៨.៤២៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧៥៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

**ឯកឧត្តម គី ធីតា**

**ជា**

**ឧកញ៉ា**

៣រល.០៩០៧.៧៣០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលសរសេរកាត់ថា **ម.ជ.ម.** ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

## ជំពូកទី២

## តួនាទីនិងភារកិច្ច

**មាត្រា២.-**

**ម.ជ.ម.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

- ជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈ ជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់
- កំណត់ពីលក្ខណសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក **ម.ជ.ម.**
- ផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ
- រៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលដៅជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- រៀបចំ ចូលរួមសិក្ខាសាលានិងវគ្គសិក្សា លើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅនិងឯកសារ សោតទស្សន៍ឬប្លុយក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ **ម.ជ.ម.**
- រៀបចំបណ្ណាល័យនិងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់មហាសន្និបាត **ម.ជ.ម.** ។

# ជំពូកទី៣

# រចនាសម្ព័ន្ធ

## ផ្នែកទី១

## មហាសន្និបាត

**មាត្រា៣.-**

សិទ្ធិអំណាចកំពូលរបស់ **ម.ជ.ម.** គឺមហាសន្និបាត។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

. រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៤៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការលុបឈ្មោះនាយទាហាន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៨ អ.ន.ក្រ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការកែសម្រួលឋានន្តរស័ក្តិ និងផ្តល់អត្តលេខយោធិន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### ស ម្រេ ច

**មាត្រា ១** : ត្រូវបានលុបឈ្មោះលោកវរសេនីយ៍ឯក **យក់ ច្រឹម** អត្តលេខ ០០០៤៦៨ នាយផ្នែកបច្ចេកទេសព្រះទីនាំង ចេញពីអង្គភាពកងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៩ តទៅ ដោយមូលហេតុបោះបង់ចោលការងារ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៥៧ .អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ និងសមិទ្ធផលផ្សេងៗជាច្រើននៅវត្តសិរីមង្គល និងវត្តពោធិព្រឹក្ស ស្ថិតក្នុងឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិៈ**

| | | | | | |
|---|---|---|---|---|---|
| ១- | អ្នកស្រី | **ហ៊ុន** | **ចាន់ថា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន១៦.៩៤២ដុល្លារ |
| ២- | អ្នកស្រី | **ចេង** | **ឡាំងហៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន១៥.៨២៥ដុល្លារ |
| ៣- | អ្នកស្រី | **ឡុង** | **ចន្ថា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន១៤.៩១០ដុល្លារ |
| ៤- | អ្នកស្រី | **កែវ** | **មុំ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន១៤.៦៤៥ដុល្លារ |
| ៥- | ឧបាសក | **ណយ** | **យីន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន១៣.៩៨៣ដុល្លារ |
| ៦- | លោក | **នួន** | **ណាត** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន១២.១៩៥ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិៈ**

| | | | | | |
|---|---|---|---|---|---|
| ១- | ព្រះតេជគុណ | **ស៊ុំ** | **សារឹម** | គង់នៅរាជធានីភ្នំពេញ | បច្ច័យចំនួន៩.៤៧៥ដុល្លារ |
| ២- | ព្រះតេជគុណ | **សែម** | **វាសនា** | គង់នៅរាជធានីភ្នំពេញ | បច្ច័យចំនួន៧.៣២៥ដុល្លារ |
| ៣- | លោក | **លឹម** | **អៀងឡាយ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៨.១៧៥ដុល្លារ |
| ៤- | អ្នកស្រី | **ឈី** | **ហាក់ស៊ុម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៧.២៦៥ដុល្លារ |

| | | | | | |
|---|---|---|---|---|---|
| ៥- | អ្នកស្រី | **ឈី** | **នេងស៊ីម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៦.៩១០ដុល្លារ |
| ៦- | អ្នកស្រី | **ញ៉ី** | **ឈាងឡូច** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន៥.៩៨៧ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៥៩ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនឧកញ៉ា **ឱក ទិជ័យ** ប្រធានអង្គការសប្បុរសជនខ្មែរ-ជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយជួសជុលដងទង់ ខ្លោងទ្វារ និងសមិទ្ធផលផ្សេងៗមួយចំនួនទៀត នៅវត្តទំពូង ឃុំមានជ័យ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកាចំនួន ១០.៤០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...១៥៦០...អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ

-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ហួយ សិទ្ធិគុណ** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៦១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ខៀវ សាម៉ន** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៦២ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតម្លើងអធិការដ្ឋានរបស់ក្រសួងបរិស្ថានទៅជាអគ្គាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ខឹម ម៉ុនហេង** អនុមន្ត្រី ថ្នាក់លេខ ៥ ឱ្យបំពេញមុខងារជាអធិការ នៃអគ្គាធិការដ្ឋាន ក្រសួងបរិស្ថាន ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៦៣.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី **Magdalena DiChiara** ប្រធានគំរោងមូលនិធិគ្លីនតុន ប្រចាំប្រទេសកម្ពុជា ដែលបានឧបត្ថម្ភថវិកាជាង ៤លានដុល្លារ លើវិស័យសុខាភិបាល សំរាប់ការផ្តល់ជំនួយជាសំភារៈនិងការគាំទ្រសកម្មភាពបង្ការការរាលដាលមេរោគអេសដី ថែទាំជំងឺអេដស៍ និងបង្ការការផ្ទុកមេរោគអេដស៍ ទៅលើកុមារនៅទូទាំងប្រទេសកម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៥ HKR

រាជធានីភ្នំពេញ ថ្ងៃទី ២[illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៦៤ . អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រី **Dr. Hildegard Lingnau** ទីប្រឹក្សាអមក្រសួងផែនការ ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្មជួយពង្រឹងសមត្ថភាពដល់ក្រសួងផែនការកន្លងមក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៩

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៦៥.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ចំនួន០១គ្រឿង ជូនអង្គការ JAPAN RISSHO KOSEI-KAI ANJO CHURCH នៅប្រទេសជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ខ្នង មាន០៩បន្ទប់ តុសិស្ស១០០ តុគ្រូ ០៥ កៅអី ០៥ របង ស្រះទឹក ជួសជុលព្រះវិហារ និងសមិទ្ធផលផ្សេងៗមួយចំនួនទៀត នៅវត្តទំពូង ឃុំមានជ័យ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកាចំនួន ៦៨.៦០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៦៨០ ឧរថ.កឌ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ១៣៩៧/០៩ គ.វ.ក ចុះថ្ងៃទី៣០.០៦.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជ្រេហ្គនថេក មេនូហ្វេកឈ័រ ចុះថ្ងៃទី១៨.០៦.២០០៩

## ស ម្រេ ច

**ប្រការ១ :**

-អនុញ្ញាតឱ្យក្រុមហ៊ុន ជ្រេហ្គនថេក មេនូហ្វេកឈ័រ តំណាងដោយ លោក CHIANG, CHIH- HAO សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 215125865 ចុះថ្ងៃទី០៧.០៥.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន No. 21, Lane 57, Sec 3, Jhongshan Road , Daiciao Village , Dacun Township Changhna Country 515,

Chaina. ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាង ក្រោម :

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| **សម្លៀកបំពាក់** | **៣២២០** |

-ផ្លាកឈ្មោះ រោងចក្រ :" **(ដ្រេហ្គនថេក មេនូហ្វេកឈ័រ ( DRAGONTEX MANUFACTURE CO., LTD.)** "

-ទីតាំងរោងចក្រ :" ***ផ្លូវទំនប់ថ្មី ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។***

**ប្រការ២ :**

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣ :**

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤ :**

-ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥ :**

-ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦ :**

-ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្ទាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណៈជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

-រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

-លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

-ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:**

-អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

**ប្រការ១៥:**

-ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ-សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ

" ដើម្បីជូនជ្រាប "

-ដូចប្រការ១៤ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ១០៥ ទសក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៩

# ប្រកាស
# ស្តីពី
# ចំណាត់ថ្នាក់សណ្ឋាគារ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១ :** ចំណាត់ថ្នាក់សណ្ឋាគារ គឺសំដៅបញ្ជាក់អំពីកម្រិតគុណភាពជាក់លាក់នៃសេវាកម្ម សម្ភារៈ និងគ្រឿងបំពាក់ដែលជាកម្មសិទ្ធិរបស់សណ្ឋាគារ អោយបានសមស្របតាមនិយាមអន្តរជាតិ ។

**ប្រការ ២ :** សេចក្តីសម្រេចផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។ ការវាយតម្លៃផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ - គឺត្រូវធ្វើឡើងតែចំពោះមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅដែលមានលក្ខណៈជាសណ្ឋាគារតែប៉ុណ្ណោះ ។

**ប្រការ ៣ :** សណ្ឋាគារទាំងអស់ត្រូវមានចំណាត់ថ្នាក់ ។ ចំណាត់ថ្នាក់សណ្ឋាគារត្រូវមានការស្នើសុំ និងបំពេញបែបបទដោយអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ។

**ប្រការ ៤ :** ចំណាត់ថ្នាក់សណ្ឋាគារ ត្រូវបានកំណត់ចាប់ពីកម្រិតអប្បបរិមាថ្នាក់ផ្កាយមួយរហូតដល់អតិបរិមាថ្នាក់ផ្កាយប្រាំ តាមប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ ។

**ប្រការ ៥ :** គោលការណ៍សំខាន់ៗ សម្រាប់វិនិច្ឆ័យផ្តល់ចំណាត់ថ្នាក់សណ្ឋាគារមាន :

- ទីតាំងស្ថាបត្យកម្ម និងទិដ្ឋភាពទូទៅ ដោយរាប់បញ្ចូលទាំងគុណភាព និងលក្ខខណ្ឌផ្នែកខាងក្រៅអគារ ទស្សនីយភាព ទីសាធារណៈក្នុងអគារ និងបន្ទប់ភ្ញៀវ
- ការបំពាក់សម្ភារៈបរិក្ខារ ដោយរាប់បញ្ចូលផ្នែកម្រាល និងជញ្ជាំង វាំងនន អគ្គីសនីបំភ្លឺ ប្រព័ន្ធប្រើប្រាស់អគ្គីសនី គ្រឿងសង្ហារឹម ព័ត៌មាន និងទូរគមនាគមន៍
- អនាម័យ និងការថែទាំ ដោយរាប់បញ្ចូលបន្ទប់ភ្ញៀវ បន្ទប់ទឹក កន្លែងសាធារណៈ កន្លែងកម្សាន្ត
- សេវា និងគុណភាពសេវា ដោយរាប់បញ្ចូលឯកសណ្ឋាន អាកប្បកិរិយារបស់បុគ្គលិកចំពោះភ្ញៀវ ការគ្រប់គ្រង និងទំនាក់ទំនងរវាងបុគ្គលិកជាមួយ និងភ្ញៀវ សុវត្ថិភាព និងសន្តិសុខភ្ញៀវ
- សេវាកម្មផ្តល់ម្ហូបអាហារ ដោយប្រើប្រាស់ផលិតផលក្នុងស្រុកដែលមានគុណភាព និងមានអនាម័យរាប់បញ្ចូលភោជនីយដ្ឋាន ការបំរើអាហារដល់បន្ទប់ គុណភាពម្ហូបអាហារ ចំនួនមុខម្ហូប ការរៀបចំតុ និងពិធីផ្សេងៗ
- ភ្លេងប្រពៃណី និងរបាំបុរាណខ្មែរ ។

**ប្រការ ៦ :** ការដាក់ពាក្យសុំចំណាត់ថ្នាក់សណ្ឋាគារ ត្រូវភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណទេសចរណ៍ និងឯកសារមួយចំនួនតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍ ព្រមទាំងត្រូវបង់ថ្លៃសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃរៀបចំចំណាត់ថ្នាក់សណ្ឋាគារ ដូចខាងក្រោម :

| | | |
|---|---|---|
| - ចំណាត់ថ្នាក់ផ្កាយប្រាំ | ១.២០០.០០០ | រៀល ( មួយលានពីរសែនរៀល) |
| - ចំណាត់ថ្នាក់ផ្កាយបួន | ១.០០០.០០០ | រៀល ( មួយលានរៀល) |
| - ចំណាត់ថ្នាក់ផ្កាយបី | ៨០០.០០០ | រៀល ( ប្រាំបីរយពាន់រៀល) |
| - ចំណាត់ថ្នាក់ផ្កាយពីរ | ៦០០.០០០ | រៀល ( ប្រាំមួយរយពាន់រៀល) |
| - ចំណាត់ថ្នាក់ផ្កាយមួយ | ៤០០.០០០ | រៀល (បួនរយពាន់រៀល) |
| - សណ្ឋាគារមិនជាប់ចំណាត់ថ្នាក់ | ២០០.០០០ | រៀល (ពីររយពាន់រៀល) |

**ប្រការ ៧ :** គំរូស្លាកសញ្ញា និងសញ្ញាចំណាត់ថ្នាក់សណ្ឋាគារត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ រីឯថ្លៃស្លាកសញ្ញាចំណាត់ថ្នាក់ ជាបន្ទុករបស់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ។

**ប្រការ ៨ :** ចំណាត់ថ្នាក់សណ្ឋាគារមានសុពលភាពរយៈពេលពីរឆ្នាំ ។ មុនពេលផុតសុពលភាពយ៉ាងតិច ៩០ថ្ងៃនៃថ្ងៃធ្វើការ អ្នកទទួលខុសត្រូវសណ្ឋាគារត្រូវដាក់ពាក្យសុំការវាយតម្លៃចាត់ថ្នាក់សណ្ឋាគារឡើងវិញ។ ចំណាត់ថ្នាក់សណ្ឋាគារនិមួយៗ អាចត្រូវតម្លើងថ្នាក់ បញ្ចុះថ្នាក់ ព្យួរ ឬ បដិសេធក្នុងរយៈពេលសុពលភាព នៃចំណាត់ថ្នាក់ ។

**ប្រការ ៩ :** ការពិនិត្យ និងវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារអាចធ្វើលើសពីមួយដង ( មិនលើសពីបីដងក្នុងវគ្គនីមួយៗ) ទៅតាមសំណូមពរចាំបាច់របស់ ម្ចាស់ រឺអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ដែលត្រូវបង់ថ្លៃការងារពិនិត្យ និងវាយតម្លៃបន្ថែមនិមួយៗ ស្មើនឹង ៧០% នៃថ្លៃកម្រិតរៀបចំចំណាត់ថ្នាក់សណ្ឋាគារដូចមានចែងក្នុងប្រការ ៦។

**ប្រការ ១០ :** ការប្រើប្រាស់ចំណាត់ថ្នាក់សណ្ឋាគារ ហួសសុពលភាព ឬការផ្សព្វផ្សាយអំពីចំណាត់ថ្នាក់សណ្ឋាគារ ដែលមិនបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ត្រូវចាត់ថាខុសច្បាប់ និងត្រូវពិន័យអន្តរការណ៍ តាមមាត្រា ៤៨ នៃច្បាប់ស្ដីពីទេសចរណ៍ ។

**ប្រការ ១១:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២ :** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថោង ខុន

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត "ដើម្បីមុខការ"
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១០៦ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៩

# ប្រកាស

## ស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ផ្កាយ ១ ផ្កាយ ២ ផ្កាយ ៣ ផ្កាយ ៤ និងផ្កាយ ៥

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងប្រកាសលេខ ១០៥ ប្រ.កចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីចំណាត់ថ្នាក់សណ្ឋាគាររបស់ក្រសួងទេសចរណ៍
- យោងសារាចរណែនាំលេខ ០០៤ ស.រ.ណ.ន ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំចំណាត់ថ្នាក់សណ្ឋាគាររបស់ក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

ក្នុងបំណងពង្រឹងវិស័យឧស្សាហកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងងាយស្រួលដល់ភ្ញៀវទេសចរសម្គាល់បានអំពីប្រភេទចំណាត់ថ្នាក់សណ្ឋាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍សម្រេចកំណត់អំពីខ្នាតគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារដូចខាងក្រោម :

**១- វត្ថុធាតុដើមនៃស្លាកសញ្ញា :**

- ផ្ទៃកផ្ទៃខាងលើ : ធ្វើអំពីស្ពាន់សន្ទឹកកម្រាស ០១ មីលីម៉ែត្រ

- ផ្នែកទ្រនាប់ខាងក្រោម : ធ្វើពីឈើប្រណិតកម្រាស ១.៥ សម និងធំជាងសន្លឹកស្ពាន់មានហាមជុំវិញ ១.៥ សម ។

**២- ទម្រង់ស្លាកសញ្ញា :**

ទម្រង់ស្លាកសញ្ញារាងបួនជ្រុងទ្រវែងបញ្ឈរ តែជ្រុងខាងលើជាខ្សែរកោង ។

**៣- ទំហំស្លាកសញ្ញា :**

- ស្ពាន់ : មានបណ្តោយ ៣៨.០០ សម x ទទឹង ២៨.០០ សម
- ឈើប្រណិត : មានបណ្តោយ ៤១.០០ សម x ទទឹង ៣១.០០ សម

**៤- របៀបរចនាស្លាកសញ្ញា :**

ក- ផ្ទៃស្លាកសញ្ញា (ក្រៅពីរូបអង្គរ ក្បាច់ ឈ្មោះស្ថាប័ន ស៊ុមឈ្មោះសណ្ឋាគារ និងស៊ុមផ្កាយ) គឺជាផ្ទៃស្ពាន់ ។

ខ- រូបអង្គរផុសមានផ្ទៃពណ៌ស្ពាន់ ចម្រុះជាមួយផ្ទៃរំលេចពណ៌ស និងមានខ្សែស្រមោលរំលេចពណ៌ខ្មៅព័ទ្ធជុំវិញ ។

គ- ចម្លាក់ក្បាច់អង្គររំលេចនៅតាមជ្រុងទាំងពីរនៃសន្លឹកស្ពាននផ្នែកខាងក្រោម លាបពណ៌ស្វាទុំ ។

ឃ-តួអក្សរអង់គ្លេស " Hotel" និងឈ្មោះសណ្ឋាគារ មានពណ៌ស្ពាន់ផុសលើស៊ុមពណ៌ទឹកប៊ិចស្រស់ ។

ង- តួរអក្សរខ្មែរ៏ ក្រសួងទេសចរណ៏កម្ពុជា៏ ប្រភេទតួរអក្សរមូលរំលេច លាបពណ៌ទឹកប៊ិចស្រស់ ។

ច- តួអក្សរ Ministry of Tourism និង Cambodia ប្រភេទតួអក្សរពុម្ពរំលេច លាបពណ៌ទឹកប៊ិចស្រស់ ។

ឆ- រូបផ្កាយកំពូលប្រាំផុសពណ៌ស្ពាន់ តំរៀបជាជួរលើស៊ុមពណ៌ទឹកប៊ិចស្រស់ ។

ជ- លេខសម្គាល់សុពលភាពសម្រាប់ពីរឆ្នាំជាលេខឡាតាំង មានផ្ទៃរំលេចលាបពណ៌ក្រហម ។

**៥- អំពីទំហំរូបក្បាច់ តួរអក្សរ និងរូបផ្កាយ :**

ក- រូបអង្គរវត្ត មានទំហំ ៦១ មម x ៣៨.២៧ មម ។

ខ- រូបក្បាច់អង្គរ ទំហំ ៦៨.៦ មម x ៦៧.១ មម នៅតាមជ្រុងទាំង ២ ផ្នែកខាងក្រោម ។

គ- ស៊ុមឈ្មោះសណ្ឋាគារ ទំហំ ២០៦ x ៨៧.៣៥ មម ។

ឃ- អក្សរ "Hotel" ទំហំ ១៥១ មម x ៣៨.២ មម ។

ង- ឈ្មោះសណ្ឋាគារ ជាអក្សរឡាតាំង ទំហំអាចប្រែប្រួលទៅតាមចំនួនតួអក្សរ តែត្រូវតូចជាងអក្សរ "Hotel" ។

ច- ស៊ុមផ្កាយ : ២០៦ មម x ៥០.៧ មម ។

ឆ- រូបផ្កាយកំពូលប្រាំ ទំហំ ៣៤.៩៥ មម x ៣៤.៩៥ មម ។

ជ- លេខសុពលភាពឆ្នាំ ទំហំ ៨៩.៦៥ មម x ១១.២ មម ។

ឈ-ឈ្មោះស្ថាប័នចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារ " ក្រសួងទេសចរណ៏ " អក្សរសរសេរជាភាសាខ្មែរ ទំហំ ៩៥ មម x ៩.៧២ មម និងអក្សរ " កម្ពុជា៏ ទំហំ ៣២.៥ មម x ៩.៧២ មម ។

ញ-ឈ្មោះស្ថាប័នចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារ ជាភាសាអង់គ្លេស " MINISTRY OF TOURISM" ទំហំ ១១១.៤ មម x ៧.៤ មម និងអក្សរ "Cambodia" ទំហំ ៦០.៤៦មម x ៧.៤ មម ។

**៦- គំលាតរវាងជួរនិមួយៗ :**

ក/-គំលាតពីលើចុះក្រោម :

- ពីគែមស្ពាន់ខាងលើ ដល់កំពូលអង្គរមានគំលាត ១០.៥ មម ។
- ពីផ្នែកខាងក្រោមអង្គរ ដល់ផ្នែកខាងលើស៊ុមអក្សរ "Hotel" មានគំលាត ១៣.៧២ មម ។
- ពីផ្នែកខាងក្រោមស៊ុមអក្សរ (Hotel) ដល់ផ្នែកខាងលើស៊ុមផ្កាយ មានគំលាត ១៥.៥ មម ។
- ពីផ្នែកខាងក្រោមស៊ុមផ្កាយ ដល់ផ្នែកខាងលើលេខឆ្នាំ មានគំលាត ២១.៣ មម ។
- ពីផ្នែកខាងក្រោមលេខឆ្នាំ ដល់ផ្នែកខាងលើអក្សរខ្មែរ ក្រសួងទេសចរណ៍ មានគំលាត ៤២ មម ។
- ពីផ្នែកខាងក្រោមអក្សរខ្មែរ " ក្រសួងទេសចរណ៍ " ដល់ផ្នែកខាងលើអក្សរ "កម្ពុជា" មានគំលាត ១២.៧៧ មម ។
- ពីផ្នែកខាងក្រោមអក្សរអង់គ្លេស " Ministry of Tourism" ដល់ផ្នែកខាងលើអក្សរ "Cambodia" មានគំលាត ១៥ មម ។
- ពីផ្នែកខាងក្រោមអក្សរកម្ពុជា និងអក្សរ Cambodia ដល់គែមស្ពាន់ខាងក្រោម មានគំលាត ៥៧.១ មម ។
- ក្បាច់អង្គរ ស្ថិតនៅជ្រុងទាំងពីរផ្នែកខាងក្រោម មានគំលាតពីគែមស្ពាន់សងខាង ៤ មម ។

ខ/-<u>គំលាតពីគែមសងខាងស្ពាន់</u> :

- រូបអង្គរ នៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ១០៩.៥ មម ។
- អំពីស៊ុមអក្សរ "Hotel" នៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ៣៧ មម ។
- អំពីស៊ុមផ្កាយនៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ៣៧ មម ។
- អំពីលេខឆ្នាំ នៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ៩៥.១៧ មម ។
- អំពីអក្សរខ្មែរ "ក្រសួងទេសចរណ៍" និងអក្សរអង់គ្លេស "Ministry of Tourism" ស្ថិតនៅចន្លោះកណ្តាលឃ្លាតពីគ្នា ៤៥ មម និងមានគំលាតពីគែមស្ពាន់សងខាង ១៤.៣ មម ។
- អំពីអក្សរខ្មែរ " កម្ពុជា" និងអក្សរអង់គ្លេស "Cambodia" ស្ថិតនៅចន្លោះកណ្តាល ឃ្លាតពីគ្នា ១០២មម ហើយអក្សរ "កម្ពុជា" មានគំលាតពីគែម ស្ពាន់ខាងឆ្វេង ៤៦.៥ មម និងអក្សរ "Cambodia" មានគំលាតពីគែមស្ពាន់ខាងស្តាំ ៣៨.៣០ មម ។

**៧-** រាល់ការប្រើប្រាស់ស្លាកសញ្ញាចំណាត់ថ្នាក់ខុសពីខ្នាតគំរូដូចបានលម្អិតខាងលើនឹងមិនមានការអនុញ្ញាតពីក្រសួងទេសចរណ៍ត្រូវហាមឃាត់ និងត្រូវពិន័យអន្តរការណ៍ តាមមាត្រា ៤៨ នៃច្បាប់ស្តីពីទេសចរណ៍ ។

ថោង ខុន

**<u>កន្លែងទទួល</u> :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត ដើម្បីជូនជ្រាប
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត ដើម្បីមុខការ
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ០០៤ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៩

## សារាចរណែនាំ

## ស្តីពីការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ

ផ្អែកលើគោលនយោបាយយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ក្នុងការជម្រុញកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ និងក្នុងគោលបំណងគ្រប់គ្រង ពង្រឹងគុណភាពសេវាកម្មស្នាក់នៅ អោយមានលក្ខណៈកាន់តែសមស្របតាមនិយាមអន្តរជាតិ ជាពិសេសការផ្តល់ព័ត៌មានពិតប្រាកដអំពីស្ថានភាពនៃលក្ខណៈសម្បត្តិ របស់សណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដល់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ ភ្ញៀវទេសចរ និងដើម្បីអនុវត្ត ប្រកាស លេខ ១០៥ ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ ក្រសួងទេសចរណ៍ធ្វើការណែនាំដូចខាងក្រោម :

១- សារាចរនេះត្រូវបានអនុវត្តចំពោះគ្រប់សណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សណ្ឋាគារដែលអាចទទួលការផ្តល់ចំណាត់ថ្នាក់បានត្រូវស្ថិតក្នុងលក្ខណៈសម្បត្តិ ដូចជា : -

- មានអាជ្ញាបណ្ណទេសចរណ៍ ដែលមានសុពលភាព
- មានវិញ្ញាបនប័ត្រធានារ៉ាប់រង
- ស្លាកឈ្មោះសណ្ឋាគារត្រូវមើលឃើញច្បាស់ដោយមានអក្សរខ្មែរធំជាងអក្សរបរទេស ដែលត្រូវកំណត់ដោយឡែកពីក្រសួងទេសចរណ៍ ។

៣- ចំណាត់ថ្នាក់សណ្ឋាគារ ត្រូវផ្តល់ចាប់ពីថ្នាក់ផ្កាយ១ រហូតដល់ផ្កាយ៥ ដែលជាចំណាត់ថ្នាក់ខ្ពស់បំផុត ។ ក្រសួងទេសចរណ៍នឹងមានការកំណត់ដោយឡែក អំពីចំណាត់ថ្នាក់ ភូមិគ្រឹះទេសចរណ៍ ប៊ីងហ្គាឡូ (Bungalow/Tourist Village), សណ្ឋាគារអាផាតម៉ិន (Hotel Apartment), ផ្ទះភ្ញៀវ (Tourist Guest House) ។

៤- នីតិវិធីនៃការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

៤-១ ការបំពេញបែបបទសុំផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ ត្រូវធ្វើឡើងដោយអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ តាមគំរូពាក្យសុំ និងលក្ខខណ្ឌផ្សេងៗ ដែលតម្រូវដោយក្រសួងទេសចរណ៍ ។

៤-២ រាល់ពាក្យស្នើសុំផ្តល់ចំណាត់ថ្នាក់ ឬសំណុំបែបបទផ្សេងៗដែលពាក់ព័ន្ធនឹងការសុំចំណាត់ថ្នាក់សណ្ឋាគារ ត្រូវទាក់ទង ឬដាក់ពាក្យសុំនៅក្រសួងទេសចរណ៍ នៅគណៈកម្មការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ "**គ.រ.ច**" ។ ការដាក់ពាក្យសុំធ្វើចំណាត់ថ្នាក់សណ្ឋាគារត្រូវបង់នៃថ្លៃធ្វើចំណាត់ថ្នាក់សណ្ឋាគារទៅតាមកម្រិតចំណាត់ថ្នាក់ដែលបានស្នើសុំ ។ មន្ទីរទេសចរណ៍រាជធានី-ខេត្ត អាចត្រូវចាត់តាំងជាកន្លែងទទួលពាក្យសុំធ្វើចំណាត់ថ្នាក់សណ្ឋាគារដែលស្ថិតនៅក្នុងតំបន់នោះ ។ ទម្រង់បែបបទទាំងអស់ត្រូវមានការចុះលេខ និងកាលបរិច្ឆេទប្រគល់-ទទួលត្រឹមត្រូវ ។

អគារលេខ ៦៣ ផ្លូវ៣៤៨ សង្កាត់ទូលស្វាយព្រៃ ២ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ២១៣ ៧៤១ ទូរសារ: +៨៥៥ ២៣ ២២០ ៧០៤ E-mail: admin@mot.gov.kh Website: www.mot.gov.kh

៤-៣ ក្នុងរយៈពេល ២០ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីទទួលបាននូវសំណុំបែបបទសុំចំណាត់ថ្នាក់សណ្ឋាគារត្រឹមត្រូវ **គ.រ.ច** ត្រូវចាត់ក្រុមការងារចុះត្រួតពិនិត្យសណ្ឋាគារជាក់ស្តែងដល់មូលដ្ឋានអាជីវកម្ម ដើម្បីប្រមូលទិន្នន័យ និងរៀបចំវាយតម្លៃអំពីចំណាត់ថ្នាក់សណ្ឋាគារ ។ ការចុះត្រួតពិនិត្យអាចត្រូវធ្វើលើសពីមួយដង ( មិនលើសពីបីដងក្នុងវគ្គនិមួយៗ ) បើសិនជាមានការចាំបាច់ ។

៤-៤ រាល់ការចុះត្រួតពិនិត្យសណ្ឋាគារ ក្រុមការងារនៃ **គ.រ.ច** ត្រូវមានបណ្ណ សម្គាល់ និងត្រូវបង្ហាញជូនអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារនូវលិខិតបេសកកម្មរបស់ **គ.រ.ច** ។ ក្រុមការងារនៃ **គ.រ.ច** ត្រូវធ្វើកំណត់ហេតុ និងរបាយការណ៍ការងារចុះត្រួតពិនិត្យ ដោយផ្តល់យោបល់អំពីលទ្ធផល នៃការវាយតម្លៃផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ ។

៤-៥ **គ.រ.ច** មានសិទ្ធិក្នុងការពិនិត្យ និងផ្តល់ចំណាត់ថ្នាក់ជំហានដំបូង ដោយត្រូវឈរលើមូលដ្ឋានពិចារណាសំខាន់ ៤ យ៉ាងគឺ :

- សំណុំបែបបទសុំធ្វើចំណាត់ថ្នាក់សណ្ឋាគារ
- កំណត់ហេតុចុះត្រួតពិនិត្យសណ្ឋាគាររបស់ក្រុមការងារ
- របាយការណ៍វាយតម្លៃរបស់ក្រុមការងារ
- ឯកសារ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀតដែលចាំបាច់ ។

**គ.រ.ច** ត្រូវចេញសេចក្តីជូនដំណឹងជាលាយលក្ខអក្សរជូនអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ អំពីការទទួលស្គាល់ស្តង់ដារជំហានដំបូងក្នុងរយៈ ២០ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីក្រុមការងារបានចុះត្រួតពិនិត្យ ។ ក្រោយរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ នៃសេចក្តីជូនដំណឹងនេះបើគ្មានការជំទាស់ជាលាយលក្ខអក្សរពីអ្នកស្នើសុំនោះទេ ការប្រកាសលទ្ធផលទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារជំហានដំបូងត្រូវចាត់ទុកជាបានការ ។ ក្រសួងទេសចរណ៍នឹងចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារជាផ្លូវការ មិនលើសពីរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ។

៤-៦ អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ មានសិទ្ធិតវ៉ាជំទាស់ជាលាយលក្ខអក្សរ ចំពោះលទ្ធផលចំណាត់ថ្នាក់សណ្ឋាគារជំហានដំបូងមក មិនអោយហួសរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។ ពេលបានទទួលពាក្យតវ៉ាជំទាស់ជាផ្លូវការ **គ.រ.ច** ត្រូវធ្វើការពិនិត្យ និងរៀបចំក្រុមការងារចុះទៅត្រួតពិនិត្យ និងវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារជាថ្មី ។

៤-៧ ក្នុងករណីសណ្ឋាគារពុំអាចបំពេញបាន តាមកម្រិតប្រព័ន្ធស្តង់ដារអប្បរមា ដូចមានចែងក្នុងអនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ នោះ **គ.រ.ច** ត្រូវធ្វើលិខិតឆ្លើយតប និងបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ជូនដល់អ្នកស្នើសុំ ។

៥- សណ្ឋាគារដែលបានទទួលស្គាល់ចំណាត់ថ្នាក់ ត្រូវធ្វើការចាត់ថ្នាក់ឡើងវិញ ក្នុងរយៈពេលមិនលើសពីពីរឆ្នាំ ។ ក្នុងករណីដែលសណ្ឋាគារណាខិតខំលើកកំពស់គុណភាពមូលដ្ឋានអាជីវកម្ម បំពាក់សម្ភារៈបរិក្ខារ និងសេវាកម្មផ្សេងៗ ឬមានការធ្លាក់ចុះដោយមិនអាចរក្សាបាននូវកម្រិតប្រព័ន្ធស្តង់ដារចំណាត់ថ្នាក់ដែលបានទទួលស្គាល់ ឬដោយមានការស្នើសុំ

ពីស្ថាប័នមានសមត្ថកិច្ច ឬអង្គការផ្សេងៗ នោះក្រសួងទេសចរណ៍នឹងពិនិត្យវាយតម្លៃចំណាត់ថ្នាក់ឡើងវិញ (តម្លើង បញ្ចុះថ្នាក់ ព្យួរ បដិសេធ) ស្របតាមទិដ្ឋភាពជាក់ស្តែងរបស់សណ្ឋាគារនោះ។

៦- **គ.រ.ច** ត្រូវធ្វើលិខិតជូនដំណឹងដល់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ដែលប្រើប្រាស់ចំណាត់ថ្នាក់សណ្ឋាគារហួសសុពលភាព ។ ករណីដែលនៅតែបន្តការប្រើប្រាស់ចំណាត់ថ្នាក់ហួសសុពលភាព នោះចាត់ទុកជាខុសច្បាប់ ។

៧- ការស្នើសុំចំណាត់ថ្នាក់សណ្ឋាគារត្រូវធ្វើនៅពេលសុំផ្តល់ ឬបន្តអាជ្ញាបណ្ណទេសចរណ៍ ។ ក្នុងករណីចាំបាច់អាជីវករអាចស្នើសុំផ្តល់ចំណាត់ថ្នាក់សណ្ឋាគារនៅក្នុងសុពលភាពនៃអាជ្ញាបណ្ណទេសចរណ៍ ។

៨- ស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារត្រូវចេញដោយក្រសួងទេសចរណ៍ រីឯថ្លៃស្លាកសញ្ញា ចំណាត់ថ្នាក់គឺជាបន្ទុករបស់ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី-ខេត្ត ដើម្បីចាត់តាំងផ្សព្វផ្សាយដល់ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារទាំងអស់អនុវត្តខ្លឹមសារសារាចរណែនាំនេះអោយមានប្រសិទ្ធភាពខ្ពស់ និងរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត "ដើម្បីមុខការ"
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៤៤២១ សសបស/ដិអបស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩

# សារាចរណែនាំ

## ស្តីពី

## ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យ ជូនភោជនីយដ្ឋាន-អាហារដ្ឋាន

- យោងសារាចរលេខ ០៣៣០អបស/ឱអបស ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងសុខាភិបាល ស្តីពីលក្ខខណ្ឌអនាម័យអាហារដ្ឋាន-ភោជនីយដ្ឋាន
- យោងសារាចរលេខ ០០៣ សរណន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្តីពីការគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន-អាហារដ្ឋាន.

ដើម្បីគ្រប់គ្រងការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនដល់ភោជនីយដ្ឋាន-អាហារដ្ឋាន អោយបានល្អប្រសើរ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដូចខាងក្រោម :

១. ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនដល់ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋានខ្នាតធំ ភោជនីយដ្ឋានខ្នាតមធ្យម Bar Bistro និងអាហារដ្ឋានទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំទៅក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

២. ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនដល់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋានខ្នាតតូច ភោជនីយដ្ឋានបៀរហ្គាដិន និងអាហារដ្ឋានក្នុងស្រុក ត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

៣. បែបបទក្នុងការស្នើសុំវិញ្ញាបនប័ត្របញ្ជាក់លើអនាម័យត្រូវអនុវត្តដូចតទៅ :
- ពាក្យស្នើសុំមានបិទតែមប្រ៊ី ១.០០០រៀល ( មានគំរូ)
- ជីវប្រវត្តិសង្ខេបរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋាន/អាហារដ្ឋាន ( មានគំរូ)
- អត្តសញ្ញាណប័ណ្ណថតចំលង ឬលិខិតឆ្លងដែនថតចំលង ( ក្នុងករណីជាជនបរទេស) របស់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋាន-អាហារដ្ឋាន
- វិញ្ញាបនប័ត្រសុខភាពរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋាន-អាហារដ្ឋាន ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត
- លិខិតបញ្ជាក់ដាក់ទីតាំងភោជនីយដ្ឋាន-អាហារដ្ឋាន ដែលចេញដោយអាជ្ញាធរមូលដ្ឋាន ( ឃុំ/សង្កាត់)
- រូបថត( ថតចំពីមុខភោជនីយដ្ឋាន-អាហារដ្ឋាន បន្ទប់បរិភោគ បន្ទប់ចំអិនចំណីអាហារ បន្ទប់រៀបចំចំណីអាហារ បន្ទប់លាងចាន និងសំភារៈផ្សេងៗ បន្ទប់ទឹក និងបង្គន់អនាម័យ) ។

៤. ក្រសួងសុខាភិបាលនឹងផ្តល់ចម្លើយអំពីការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យ ក្នុងការសុំបើក សុំប្តូរទីតាំង និង សុំផ្លាស់ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន-អាហារដ្ឋាន ដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ យ៉ាងយឺតបំផុតរយៈពេល៣០ថ្ងៃ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលសំណុំលិខិតគ្រប់គ្រាន់។

ទទួលបាននូវសារាចរណែនាំនេះ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយណែនាំអោយបានទូលំទូលាយដល់ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ក្នុងការអនុវត្តនីអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ម៉ម_ប៊ុនហេង

<u>ចំលងជូនៈ</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងទេសចរណ៍
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- គ្រប់សាលារាជធានី-ខេត្ត
- ខុទ្ទការល័យក្រសួងសុខាភិបាល
- អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- អគ្គនាយកបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- មន្ទីសុខាភិបាលរាជធានី-ខេត្ត
- ឯកសារ និងកាលប្បវត្តិ